*(Unofficial Translation)*

**Kingdom of Cambodia**

**Nation Religion King**

**Royal Government of Cambodia**

**No. 49 SSR**

**Decision**
**On**
**Putting Phnom Penh and Takhmao City on Lockdown in order to Prevent the Spread of COVID-19**

**Royal Government**

- Having seen the Constitution of the Kingdom of Cambodia;
- Having seen Royal Decree No. NS/RKT/0918/925, dated 06 September 2018, on the appointment of the Royal Government of the Kingdom of Cambodia;
- Having seen Royal Decree No. NS/RKT/0320/421, dated 30 March 2020, on the appointment and reshuffle of the Royal Government members, the Kingdom of Cambodia;
- Having seen Royal Kram No. NS/RKM/0618/012, dated 28 June 2018, promulgating the Law on the Organization and Functioning of the Council of Ministers;
- Having seen Royal Kram No. NS/RKM/0321/004, dated 11 March 2021, promulgating the Law on Preventive Measures against the Spread of COVID-19 and other Severe and Dangerous Contagious Diseases;
- Having seen Sub-Decree No.37 ANK-BK, dated 12 March 2021, on Health Measures for Preventing the Spread of COVID-19 and other Severe and Dangerous Contagious Diseases;
- Having seen Sub-Decree No.57 ANK-BK, dated 31 March 2021, on Administrative Measures for Preventing the Spread of COVID-19 and other Severe and Dangerous Contagious Diseases;
- Based on the necessity of Combatting and Preventing the Spread of COVID-19

**Hereby decided**

**Article 1**

To temporarily put Phnom Penh and Takhmao City on lockdown for 14 days effective from 12:00 am on 15 till 28 April 2021 in order to ensure the effectiveness of controlling the spread

of COVID-19 in Phnom Penh Capital and Takhmao City and to prevent the further spread of COVID-19 to other areas.

Phnom Penh Capital and Takmao City shall be considered a single geographical location that shall be under lockdown.

**Article 2**

During lockdown, individuals are prohibited from going out of their home or current residence if unnecessary except for the following circumstances:

- Travels to perform work or employment or business activities in lockdown locations, which are not prohibited in Article 3 and with a work permit/certificate issued by the concerned workplace, business or the nearest competent authority;
- Travels to buy foods, groceries or basic necessities from shops/businesses allowed to operate by the competent authority. For these travels, only two people maximum per household, three times per week at most and within their residential district/khan shall be allowed. Khmer ID or other ID cards shall be brought along;
- Travels to hospitals, health centres, maternities, treatment facilities or pharmacies for medical reasons within the lockdown areas. The travels for medical reasons within the lockdown areas shall be permitted by the authorities implementing the lockdown measures, allowing no more than 4 people per case and shall strictly adhere to health measures especially mask wearing and physical distancing;
- Travels to present oneself before health officials for sample collection and COVID-19 testing and scheduled COVID-19 vaccination within or outside of the lockdown areas;
- Travels to perform an activity in public interests or other necessary purposes as requested or required by a public authority;
- Individual sporting activity within their residential area that does not involve a gathering of more than two people;
- Travels by diplomats, staff of foreign embassies, United Nations agencies, international financial institutions, international organizations and international Non-Governmental Organizations along with work certificate and ID cards;
- Travels by journalists along with work certificate and ID cards;
- Entry and exit travels to lockdown areas by air that comply with provisions and health measures in force; and
- Other urgent and necessary travels permitted in advance by a competent authority implementing the lockdown measures

In all the above-mentioned exceptional circumstances, every individual shall be required to wear a mask and keep a physical distance and adhere to sanitation and temperature screening.

**Article 3**
During lockdown, employment, professional and business activities that are not basic necessities shall be prohibited with the following exceptions:

- Activities by public institutions and armed forces. However, the concerned institution shall limit the number of staff to a minimum in order to ensure the sustainable functioning of the institution. Head of the institution may decide to suspend any unnecessary work as apparently required;
- Factories, enterprises, handicrafts or food and grocery processing facilities including slaughterhouses that produce basic necessities;
- Activities pertaining to provisions of public service, including fire service, electricity and water supplies, rubbish collection as well as rubbish-solid waste transportation;
- All online employment, profession and business activities;
- Deliveries/supplies of basic necessities, including goods shops, wholesale and retail markets, organized groceries supermarkets and shops, marts and restaurants and canteens selling takeaway, petroleum and gas stations or suppliers of other daily necessities permitted by a competent authority;
- Supplies of basic necessities, including emergency service, health and pharmacy service, post-telecommunication, bank and financing service, and other basic daily services permitted by a competent authority but shall be subject to limited number of staff;
- Guesthouse and hotel services;
- Delivery services serving in the lockdown areas;
- Entry-exit goods transportation or transit transportation services serving the country's socio-economic sectors; and
- Employment, profession or business activities permitted by a competent authority

In all the above-mentioned exceptional circumstances, every individual shall be required to wear a mask and keep a physical distance and adhere to sanitation and temperature screening.

**Article 4**
During lockdown, any meeting or gathering of people shall be prohibited except for the following circumstances:

- A gathering of family members in the same household or sharing the same residence;
- A funeral permitted by a competent authority;
- Gathering of people and health workers aimed at implementing health measures, such as sample collection for COVID-19 testing and COVID-19 vaccination and other gatherings of health workers performing emergency work; and
- A gathering of competent authorities, all levels of forces performing security and public order duties

In all the above-mentioned exceptional circumstances, every individual shall be required to wear a mask and maintain a physical distance and adhere to sanitation and temperature screening except for family members in the same household or residence.

**Article 5**

Any travel permitted in Article 2 of this Decision shall not be allowed between 20:00 pm to 5:00 am except for urgent and necessary medical and family travels, transportation of goods, work performance in public interests, travels to and from performing work at enterprises, establishments or businesses exempted to operate as stipulated in the following Paragraph and in other necessary circumstances permitted by competent authority.

Every public enterprise, private establishment or business location permitted to operate in accordance with Article 3 of this Decision shall suspend from 20:00 pm to 5:00 am their direct customer service except for emergency, health, pharmacy, petroleum, hotel and hothouse and other necessary services permitted by a competent authority.

Entry into and exit from lockdown areas shall be prohibited except for travels to perform emergency functions, necessary and urgent public services, security and public order duties, delivery and other necessary services permitted by a competent authority.

**Article 6**

To establish a National Committee to Manage and Lead the Implementation of the Lockdown Measures, abbreviated as C.L.D with the following composition:

| | | |
|---|---|---|
| 1. H.E Orn Pornmoniroth | Deputy Prime Minister, Minister of Economy and Finance | Chair |
| 2. H.E Prof Mam Bunheng | Minister of Health | Vice chair |
| 3. H.E Keut Rith | Minister of Justice | Vice chair |
| 4. H.E General Neang Phat | Permanent Secretary of State of Ministry of National Defence | Vice chair |
| 5. H.E Sak Setha | Permanent Secretary of State of Ministry of Interior | Vice chair |
| 6. H.E Khuong Sreng | Governor of the Board of Governor of Phnom Penh | Permanent vice chair |
| 7. H.E Pan Sosak | Minister of Commerce | Member |
| 8. H.E Vorng Soth | Minister of Social Affairs and Youth Rehabilitation | Member |
| 9. H.E Ith Samheng | Minister of Labour and Vocational Training | Member |
| 10. Mao Havannal | Minister in charge of the Secretariat of Civil Aviation | Member |
| 11. Uoch Borith | Minister attached to the Prime Minister and Permanent Secretary of State of | Member |

| | | |
|---|---|---|
| | Ministry of Foreign Affairs and International Cooperation | |
| 12. H.E Svay Sitha | Minister attached to the Prime Minister and Head of the Press and Quick Reaction Unit | Member |
| 13. Uk Prathna | Secretary of State of Ministry of Information | Member |
| 14. H.E General Vong Pisen | Commander in Chief of the Cambodian Royal Armed Forces | Member |
| 15. H.E General Neth Savoeurn | General Commissioner of the National Police | Member |
| 16. H.E General Ith Sarath | Deputy Commander in Chief and Chief of Staff of the Cambodian Royal Armed Forces | Member |
| 17. H.E Lieutenant General Hun Manet | Deputy Commander in Chief of the Cambodian Royal Armed Forces and Commander of the Army | Member |
| 18. H.E Sao Sokha | Deputy Commander in Chief of the Cambodian Royal Armed Forces and Commander of the Gendarmery | Member |
| 19. H.E Kong Sophorn | Governor of the Board of Governors of Kandal | Member |

In urgent cases, the chair of C.L.D has the right to invite dignities representing other concerned ministries and institutions to attend a meeting or provide advice as required.

C.L.D may establish sub committees as deemed necessary by decisions of the Royal Government as proposed by the chair of C.L.D.

C.L.D shall have an executive committee as its secretariat in charge of implementing the lockdown measures.

**Article 7**

The National Committee to Manage and Lead the Implementation of Lockdown Measures has the following duties:

- Set out detailed measures or instructions aimed at ensuring the effective implementation of lockdown measures and control the spread of COVID-19 in the lockdown areas and prevent the disease from spreading to other areas;
- Set out policies and measures to support and safeguard victims and vulnerable people during lockdown;
- Provide support to the Executive Committee of C.L.D in liaising with concerned ministries and institutions with a view to ensuring smooth and effective implementation of lockdown measures;

- Implement other necessary measures as assigned by the Head of the Royal Government; and
- Regularly report to the Head of the Royal Government on results and challenges facing the implementation of lockdown measures

**Article 8**
The Board of Governors of Phnom Penh and Board of Governors of Kandal shall be designated as the Executive Committee, which is the Secretariat of the C.L.D, to take charge of implementation of the lockdown measures in accordance with this Decision. This Executive Committee shall be led by Governor of the Board of Governors of Phnom Penh on general matters and with the Governor of the Board of Governor of Kandal as vice chair in charge of lockdown in Takhmao City area.

The Executive Committee of C.L.D shall have the right to establish certain necessary working groups to ensure effective implementation of the lockdown measures within their jurisdiction. Ministries and institutions shall assign their representatives to lead and/or participate in the working groups as requested the chair of the C.L.D Executive Committee within their expertise and responsibility in order to ensure effective implementation of the lockdown measures and control of the spread of COVID-19 within the lockdown areas and to other areas.

The Executive Committee of the C.L.D has the right to use the stamp of the Phnom Penh Municipal Administration in the performance of their duties.

**Article 9**

All regulations concerning administrative measures aimed at combating and preventing the spread of COVID-19, issued prior to the entry in force of this Decision and which are not contrary to this Decision shall remain effective and enforceable until otherwise replaced by other newly issued regulations.

**Article 10**
Any provision contrary to this Decision shall be abrogated.

**Article 11**
Minister in charge of the Council of Ministers, Minister of Economy and Finance, Minister of Interior, Minister of National Defence, Health, Minister of Justice, all ministers and heads of institutions shall implement this Decision in their capacity from the date of this signature onwards.

Phnom Penh, 14 April 2021

**Prime Minister**

*(Unofficial Translation)*

Signature and Seal

***Samdech Akka Moha Sena Padei Techo* Hun Sen**

**CC:**
- Ministry of Royal Palace
- General Secretariat of the Constitutional Council
- General Secretariat of the Senate
- General Secretariat of the National Assembly
- Cabinet of *Samdech Akka Moha Sena Padei Techo* Prime Minister
- Cabinet of *Samdech,* Her/His Excellency Deputy Prime Ministers
- As Stipulated in Article 11
- Royal Gazette
- Records – Archives

*(Unofficial Translation)*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១** ..

ត្រូវបានបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ជាបណ្តោះអាសន្នសម្រាប់រយៈពេល ១៤ថ្ងៃ គិតចាប់ពីវេលាម៉ោងសូន្យនាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ក្នុងគោលបំណងធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល និងទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ត្រូវចាត់ទុកជាភូមិសាស្ត្រតែមួយដែលត្រូវបានបិទខ្ទប់។

**ប្រការ២** ..

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់នេះ បុគ្គលគ្រប់រូបត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្នរបស់ខ្លួន ប្រសិនបើគ្មានការចាំបាច់។

ប៉ុន្តែ ការធ្វើដំណើរចេញក្រៅពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរ ឬអាជីវកម្មក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ដែលមិនមានការហាមឃាត់ដូចបានកំណត់ក្នុងប្រការ៣ និងដោយមានភ្ជាប់ឯកសារបញ្ជាក់អំពីការងារ មុខរបរ ឬអាជីវកម្ម ដែលចេញដោយទីកន្លែងអាជីវកម្មពាក់ព័ន្ធ ឬអាជ្ញាធរដែនដីដែលមានទីតាំងនៅជិតបំផុត
- ការធ្វើដំណើរទៅកាន់ទីកន្លែងលក់ម្ហូបអាហារ ឬគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃដែលអនុញ្ញាតឱ្យបើកដំណើរការដោយអាជ្ញាធរមានសមត្ថកិច្ច។ ការធ្វើដំណើរក្នុងគោលបំណងនេះ អាចធ្វើឡើងដោយសមាជិកយ៉ាងច្រើន ២ (ពីរ) នាក់ ក្នុងមួយលំនៅឋានឬទីសំណាក់ មិនឱ្យលើសពី ៣(បី) ដង ក្នុងមួយសប្តាហ៍ និងនៅទីតាំងដែលជិតបំផុតក្នុងរង្វង់ភូមិសាស្ត្រក្រុង ឬខណ្ឌដែលខ្លួនរស់នៅ ដោយត្រូវយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬប័ណ្ណសម្គាល់ខ្លួន
- ការធ្វើដំណើរទៅមន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភព ទីកន្លែងព្យាបាល ឬឱសថស្ថាន ដោយមូលហេតុសុខភាពបន្ទាន់ នៅក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់។ ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់នេះ ចេញក្រៅឬចូលក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ អាចធ្វើទៅបានដោយមានការអនុញ្ញាតពីអាជ្ញាធរដែលអនុវត្តវិធានការបិទខ្ទប់ ដោយកំណត់ចំនួនមនុស្សមិនឱ្យលើសពី ៤ (បួន) នាក់សម្រាប់ករណីនីមួយៗ ប៉ុន្តែត្រូវអនុវត្តដាច់ខាតនូវកាតព្វកិច្ចទាក់ទងនឹងវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព
- ការធ្វើដំណើរដើម្បីទៅបង្ហាញខ្លួនឱ្យមន្ត្រីសុខាភិបាលធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងដើម្បីទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ តាមកាលកំណត់ និងនៅក្នុង ឬចេញក្រៅរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់
- ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរសាធារណៈ

- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្ត្រភូមិដែលខ្លួនរស់នៅ ដោយចៀសវាងការជួបជុំមនុស្សលើសពី ២ (ពីរ) នាក់
- ការធ្វើដំណើររបស់មន្ត្រីការទូត មន្ត្រីបុគ្គលិកនៃស្ថានតំណាងបរទេស ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការហិរញ្ញវត្ថុអន្តរជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបរទេស ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ
- ការធ្វើដំណើររបស់អ្នកសារព័ត៌មាន ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ
- ការធ្វើដំណើរចេញ-ចូលតំបន់បិទខ្ទប់តាមផ្លូវអាកាស ដោយត្រូវគោរពតាមបទប្បញ្ញត្តិ និងវិធានការសុវត្ថិភាពផ្នែកសុខាភិបាលជាធរមាន និង
- ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ផ្សេងទៀត ដោយមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។

រាល់ការលើកលែងខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមាន ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្ដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ៣** ..

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ត្រូវបានហាមឃាត់រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មទាំងអស់ ដែលមិនមែនជាតម្រូវការចាំបាច់ប្រចាំថ្ងៃ។

ប៉ុន្តែ សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- សកម្មភាពការងាររបស់ស្ថាប័នសាធារណៈ និងកងកម្លាំងប្រដាប់អាវុធ ប៉ុន្តែប្រធានស្ថាប័នសាមីត្រូវកាត់បន្ថយចំនួនអ្នកធ្វើការឱ្យមកនៅត្រឹមកម្រិតអប្បបរមា ដើម្បីធានានិរន្តរភាពការងាររបស់ស្ថាប័ន។ ប្រធានស្ថាប័នអាចសម្រេចផ្អាកការងារដែលមិនចាំបាច់ជាបណ្ដោះអាសន្ន តាមការជាក់ស្តែង
- រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតម្ហូបអាហារ និងគ្រឿងឧបភោគបរិភោគ ដោយរួមទាំងទីសត្តឃាត ដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ
- សកម្មភាពការងារដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ តាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអាទិ៍ សេវាពន្លត់អគ្គិភ័យ, សេវាផ្គត់ផ្គង់អគ្គិសនី, ទឹកស្អាត, សេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង ជាដើម
- រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ
- ការផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ហាងលក់ទំនិញ ផ្សារលក់ដុំ ផ្សារឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគដែលមានសណ្តាប់ធ្នាប់ ផ្សារម៉ាត និងភោជនីយដ្ឋាន-អាហារដ្ឋានដែលលក់ជាអាហារវេចខ្ចប់, ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស ឬទីតាំងផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច
- ការផ្គត់ផ្គង់សេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ សេវាសង្គ្រោះបន្ទាន់, សេវាសុខាភិបាល និងឱសថស្ថាន, សេវាប្រៃសណីយ៍-ទូរគមនាគមន៍, សេវាធនាគារ និងហិរញ្ញវត្ថុ និងសេវាដែលជា

*(Unofficial Translation)*

តម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ប៉ុន្តែ ត្រូវកាត់បន្ថយចំនួនបុគ្គលិកបម្រើការឱ្យមកនៅត្រឹមកម្រិតអប្បបរមា

- សេវាកម្មសណ្ឋាគារ និងផ្ទះសំណាក់
- សេវាកម្មដឹកជញ្ជូនទំនិញចាំបាច់ដើម្បីបម្រើឱ្យភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់
- សេវាកម្មដឹកជញ្ជូនទំនិញទូទៅចេញ-ចូល ឬឆ្លងកាត់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ដើម្បីបម្រើឱ្យវិស័យសង្គម-សេដ្ឋកិច្ចនៃប្រទេស និង
- សកម្មភាពការងារ មុខរបរ ឬអាជីវកម្មចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលត្រូវបានអនុញ្ញាតដូចបានរៀបរាប់ខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមានការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្តៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ៤.-**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ត្រូវហាមឃាត់រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស។ ប៉ុន្តែ ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា
- ការរៀបចំពិធីបុណ្យសព ដោយគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច
- ការប្រមូលផ្តុំមនុស្ស និងការជួបជុំរបស់បុគ្គលិកសុខាភិបាល ដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកមកវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងការជួបជុំរបស់បុគ្គលិកសុខាភិបាលដែលបំពេញការងារសង្គ្រោះបន្ទាន់ផ្សេងទៀត និង
- ការជួបជុំរបស់អាជ្ញាធរមានសមត្ថកិច្ច កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ក្នុងការបំពេញការងារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។

រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្សដែលត្រូវបានអនុញ្ញាតដូចបានរៀបរាប់ខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចកិច្ចត្រូវអនុវត្តនូវវិធានការសុខាភិបាល ជាពិសេសការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្តៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ លើកលែងតែចំពោះការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា។

**ប្រការ៥.-**

រាល់ការធ្វើដំណើរដែលត្រូវបានអនុញ្ញាតដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចនេះ មិនត្រូវធ្វើឡើងនៅចន្លោះពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) លើកលែងចំពោះការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់ មូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ, ការដឹកជញ្ជូនទំនិញ, ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ, ការធ្វើដំណើរទៅនិងមកពីទីកន្លែងបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ឬទីតាំងអាជីវកម្មដែលត្រូវបានលើកលែងឱ្យបើកដំណើរការដូចមានចែងក្នុងកថាខណ្ឌខាងក្រោមនេះ និងករណីចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

*(Unofficial Translation)*

រាល់គ្រឹះស្ថានសាធារណៈ សហគ្រាសឬគ្រឹះស្ថានឯកជន ឬទីតាំងអាជីវកម្មដែលត្រូវបានអនុញ្ញាតឱ្យនៅបើកដំណើរការស្របតាមប្រការ៣ នៃសេចក្តីសម្រេចនេះ ត្រូវផ្អាកប្រតិបត្តិការរបស់ខ្លួនចាប់ពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) សម្រាប់ទទួលអតិថិជនដោយផ្ទាល់ លើកលែងចំពោះសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ឱសថស្ថាន ស្ថានីយ៍ប្រេងឥន្ធនៈ សេវាសណ្ឋាគារ និងផ្ទះសំណាក់ និងសេវាសាធារណៈចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរ មានសមត្ថកិច្ច។

ការធ្វើដំណើរចេញ-ចូលឆ្លងកាត់ព្រំប្រទល់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ត្រូវបានហាមឃាត់ លើកលែងតែការធ្វើដំណើរដើម្បីបំពេញមុខងារក្នុងការផ្តល់សេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ សេវាពាក់ព័ន្ធនឹងការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ឬសេវាដឹកជញ្ជូនទំនិញ និងករណីចាំបាច់ផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៦** ..

ត្រូវបានបង្កើតគណៈកម្មការជាតិគ្រប់គ្រងនិងដឹកនាំការអនុវត្តវិធានការបិទខ្ទប់ សរសេរជាអក្សរកាត់ថា "**គ.ប.ខ.**" ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៣-ឯកឧត្តម **កើត រិទ្ធ** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** | រដ្ឋលេខាធិការប្រចាំការក្រសួងការពារជាតិ | អនុប្រធាន |
| ៥-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦-ឯកឧត្តម **ឃួង ស្រេង** | អភិបាលនៃគណៈអភិបាល រាជធានីភ្នំពេញ | អនុប្រធានអចិន្ត្រៃយ៍ |
| ៧-ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨-ឯកឧត្តម **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩-ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០-ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១១-ឯកឧត្តម **អ៊ុច បូររិទ្ធ** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១២-ឯកឧត្តម **ស្វាយ ស៊ីថា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣-ឯកឧត្តម **អ៊ុក ប្រាជ្ញា** | រដ្ឋលេខាធិការប្រចាំការក្រសួងព័ត៌មាន | សមាជិក |

*(Unofficial Translation)*

| | | |
|---|---|---|
| ១៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **វង្ស ពិសេន** | អគ្គមេបញ្ជាការនៃកងយោធពល ខេមរភូមិន្ទ | សមាជិក |
| ១៥-ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** | អគ្គមេបញ្ជាការរង និងជានាយសេនាធិការ ចម្រុះ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៧-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរ ភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ១៨-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | អគ្គមេបញ្ជាការរងនៃកងយោធពល ខេមរភូមិន្ទ និងជាមេបញ្ជាការកង រាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៩-ឯកឧត្តម **គង់ សោភ័ណ្ឌ** | អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល | សមាជិក |

ក្នុងករណីចាំបាច់ ប្រធាន **គ.ម.ខ.** មានសិទ្ធិអញ្ជើញឥស្សរជនជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមប្រជុំ ឬផ្ដល់យោបល់តាមការចាំបាច់។

**គ.ម.ខ.** អាចមានអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដែលត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធាន **គ.ម.ខ.**។

**គ.ម.ខ.** មានគណៈកម្មការប្រតិបត្តិមួយជាសេនាធិការទទួលបន្ទុកក្នុងការអនុវត្តវិធានការបិទខ្ទប់។

**ប្រការ៧** ..

គណៈកម្មការជាតិគ្រប់គ្រង និងដឹកនាំការអនុវត្តវិធានការបិទខ្ទប់ មានភារកិច្ច ដូចខាងក្រោម៖

- ដាក់ចេញនូវវិធានការលម្អិត ឬការណែនាំលម្អិតនានា សំដៅធានាដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការបិទខ្ទប់ និងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលត្រូវបានបិទខ្ទប់ ក៏ដូចជាទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត
- ដាក់ចេញនូវគោលនយោបាយ និងវិធានការដើម្បីគាំពារ និងជួយសង្គ្រោះដល់ជនក្រីក្រ និងជនងាយរងគ្រោះក្នុងអំឡុងពេលបិទខ្ទប់
- ជួយគាំទ្រដល់គណៈកម្មការប្រតិបត្តិរបស់ **គ.ម.ខ.** ក្នុងការសម្របសម្រួលជាមួយក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធសំដៅធានាការអនុវត្តវិធានការបិទខ្ទប់ឱ្យបានរលូន និងមានប្រសិទ្ធភាព
- អនុវត្តនូវវិធានការចាំបាច់ផ្សេងទៀតតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល
- រាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាលអំពីលទ្ធផល និងបញ្ហាប្រឈមនានាក្នុងការអនុវត្តវិធានការបិទខ្ទប់។

**ប្រការ៨** ..

ត្រូវបានប្រគល់ភារកិច្ចជូនគណៈអភិបាលរាជធានីភ្នំពេញ និងគណៈអភិបាលខេត្តកណ្ដាល ដើម្បីធ្វើជាគណៈកម្មការប្រតិបត្តិដែលជាសេនាធិការឱ្យ **គ.ម.ខ.** ក្នុងការទទួលបន្ទុកអនុវត្តវិធានការបិទខ្ទប់ស្របតាមសេចក្ដីសម្រេចនេះ។ គណៈកម្មការប្រតិបត្តិនេះ ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញទទួលបន្ទុករួម និងមានអភិបាលនៃគណៈអភិបាលខេត្តកណ្ដាលជាអនុប្រធានទទួលបន្ទុកការងារបិទខ្ទប់សម្រាប់ភូមិសាស្ត្រក្រុងតាខ្មៅ។

*(Unofficial Translation)*

គណៈកម្មការប្រតិបត្តិនៃ **គ.ប.ខ.** មានសិទ្ធិបង្កើតក្រុមការងារមួយចំនួនតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តវិធានការបិទខ្ទប់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។ ក្រសួង ស្ថាប័ននានា ត្រូវចាត់បញ្ជូនតំណាងរបស់ខ្លួនដើម្បីដឹកនាំ និង/ឬចូលរួមក្នុងក្រុមការងារតាមការស្នើសុំរបស់ប្រធានគណៈកម្មការប្រតិបត្តិនៃ **គ.ប.ខ.** ក្នុងក្របខណ្ឌនៃសមត្ថកិច្ចជំនាញ និងការទទួលខុសត្រូវរបស់ខ្លួន ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការបិទខ្ទប់ និងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលត្រូវបានបិទខ្ទប់ ក៏ដូចជាទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

គណៈកម្មការប្រតិបត្តិនៃ **គ.ប.ខ.** មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៩ ..**

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការរដ្ឋបាលនានា ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលសេចក្តីសម្រេចនេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

**ប្រការ១០ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣ កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ